# ពាក្យអធិដ្ឋានសម្រាប់ធម៌មេត្តាករុណារបស់សន្តីហ្វូស្ទីណា

ឱព្រះអម្ចាស់អើយ! សូមព្រះអង្គជួយខ្ញុំឲ្យមើលអ្នកដទៃដោយចិត្តមេត្តាករុណា កុំឲ្យខ្ញុំសង្ស័យអំពីនរណាសោះ និងកុំវិនិច្ឆ័យគេតាមអាការខាងក្រៅ តែឲ្យខ្ញុំចេះពិចារណាមើលសោភ័ណភាពនៅក្នុងចិត្តអ្នកដទៃ និងចេះជួយគេផង។

សូមឲ្យខ្ញុំចេះស្តាប់អ្នកដទៃដោយចិត្តមេត្តាករុណា យកចិត្តទុកដាក់នឹងសេចក្តីត្រូវការរបស់គេ កុំឲ្យខ្ញុំបិទត្រចៀកមិនរវីរវល់នឹងទុក្ខលំបាក និងពាក្យត្អូញត្អែររបស់គេឡើយ។

សូមឲ្យខ្ញុំចេះនិយាយពាក្យប្រកបដោយធម៌មេត្តាករុណា កុំឲ្យខ្ញុំមួលបង្កាច់អ្នកដទៃតែផ្ទុយទៅវិញ សូមព្រះអង្គប្រោសឲ្យខ្ញុំចេះនិយាយពាក្យលួងលោមចិត្តគេ និងលើកលែងទោសឲ្យគេផង។

សូមឲ្យខ្ញុំយកចិត្តទុកដាក់ធ្វើការដោយចិត្តមេត្តាករុណា និងប្រព្រឹត្តអំពើល្អដល់គេ។

សូមឲ្យខ្ញុំយកចិត្តទុកដាក់ប្រញាប់ប្រញាល់ដើរជួយអ្នកដទៃ ទាំងបំភ្លេចការហត់នឿយរបស់ខ្លួន និងដោយមិនណាយចិត្តឡើយ។

សូមឲ្យខ្ញុំមានចិត្តមេត្តាករុណា សុខចិត្តរងទុក្ខលំបាកទាំងប៉ុន្មានរួមជាមួយអ្នកដទៃ ទុកជាទុក្ខលំបាករបស់ខ្លួនខ្ញុំផ្ទាល់។ អាម៉ែន៕